ឧបសម្ព័ន្ធទី ៣: ការងារនៅថ្នាលបណ្តុះកូនឈើ

ឧបសម្ព័ន្ធទី ៤: ការងារនៅចំការដាំឈើ

ឧបសម្ព័ន្ធទី ៥: ការថែរក្សាចំការឈើដាំ

ឧបសម្ព័ន្ធទី ៨: វិធីសាស្ត្រក្នុងការជ្រើសរើសប្រភេទឈើសំរាប់ដាំដើម្បីកាត់បន្ថយភាពក្រីក្រ

ឧបសម្ព័ន្ធទី ១០: ប្រភេទឈើមួយចំនួនដែលផ្តល់ផលិតផលបន្ថែមក្រៅពីឈើ

ទំព័របន្ថែមទី១: ការគណនាតំរូវការគ្រាប់ពូជឈើ

# ៧. ការដាំឈើជាចំការតូចៗដោយកសិករ

## ៧.១ យុត្តិកម្ម

ភាពខ្សត់ខ្សោយនៃធនធានព្រៃឈើនៅក្នុងមូលដ្ឋាន បានផ្តល់ឱកាសឱ្យកសិកររិះរកប្រាក់ចំណូលបន្ថែមទៀតតាមរយៈការងារដាំឈើ ។ នៅក្នុងតំបន់ខ្លះនៃប្រទេសកម្ពុជា ដូចជាខេត្តកំពង់ឆ្នាំង និងតាកែវ កសិករចាប់ផ្តើមការងារដាំឈើនៅលើដីកម្មសិទ្ធិរបស់ខ្លួនដោយគ្មានឬមានជំនួយតិចតួចប៉ុណ្ណោះពីអ្នកផ្តល់ជំនួយនានា ។ ការងារដែលចាប់ផ្តើមដោយកសិករនេះអាចសំរេចបានជោគជ័យដោយសារមូលហេតុពីរយ៉ាងគឺ: ទីមួយ ដោយសារកសិករមានធនធានថវិកាតិចតួច ដូច្នេះរាល់ដើមឈើដែលបានដាំតំណាងឱ្យការយល់ដឹងក្នុងការធ្វើវិនិយោគ ព្រោះថាគាត់អាចមានជំរើសក្នុងការប្រើប្រាស់ដីផ្សេងៗទៀត ។ ទីពីរ កសិករដាំដើមឈើតែក្នុងបរិមាណមួយដែលអាចថែរក្សាបានដោយគត់មត់ ។ ហេតុផលដែលនាំឱ្យកសិករតូចតាចចូលរួមក្នុងការងារដាំឈើគឺ ដោយសារគាត់មានចំណាប់អារម្មណ៍ក្នុងការពង្រឹងជីវភាពគ្រួសារតាមរយៈការបង្កើតផលិតផលឈើសំរាប់ប្រើប្រាស់ក្នុងគ្រួសារនិងសំរាប់លក់ដូរ ។

## ៧.២. ការអនុវត្តន៍

កសិករម្នាក់ឬមួយក្រុមអាចបង្កើតចំការឈើដែលផ្តល់ផលច្រើនប្រភេទ ដូចជាឈើសំណង់ សរសរ អុស ចំណីសត្វ និងផលិតផលមិនមែនឈើជាច្រើនប្រភេទទៀតសំរាប់ការប្រើប្រាស់ក្នុងគ្រួសារនិងសំរាប់លក់ដូរ ។ ចំការឈើក៏អាចជួយការពារបរិស្ថានចំការដំណាំដោយបង្កើនគុណភាពដី ការពារការហូរច្រោះ ផ្តល់ម្លប់ដល់មនុស្សនិងសត្វក៏ដូចជាបង្កើនគុណភាពបរិស្ថានទូទៅផងដែរ ។

សូមមើលឧបសម្ព័ន្ធទី ៩ សំរាប់ដំណើរការជ្រើសរើសប្រភេទឈើឱ្យបានសមស្រប និងតារាងទី២ នៃឧបសម្ព័ន្ធទី ១១ សំរាប់ឧទាហរណ៍នៃប្រភេទឈើដែលផ្តល់ផលិតផលក្រៅពីឈើជាច្រើនប្រភេទ ។

***សូមប្រើប្រាស់ទំព័របន្ថែម និង ឧបសម្ព័ន្ធនានាដូចខាងក្រោម:***

ឧបសម្ព័ន្ធទី ១: ការជ្រើសរើសប្រភេទឈើ

ឧបសម្ព័ន្ធទី ២: លទ្ធកម្មគ្រាប់ពូជ

ឧបសម្ព័ន្ធទី ៣: ការងារនៅថ្នាលបណ្ដុះកូនឈើ

ឧបសម្ព័ន្ធទី ៤: ការងារនៅចំការដាំឈើ

ឧបសម្ព័ន្ធទី ៥: ការថែរក្សាចំការឈើដាំ

ឧបសម្ព័ន្ធទី ៨: វិធីសាស្ត្រក្នុងការជ្រើសរើសប្រភេទឈើសំរាប់ដាំដើម្បីកាត់បន្ថយភាពក្រីក្រ

ឧបសម្ព័ន្ធទី ៩: ចំណង់ចំណូលចិត្តរបស់កសិករក្នុងការជ្រើសរើសប្រភេទឈើសំរាប់ដាំ

ឧបសម្ព័ន្ធទី ១០: ប្រភេទឈើមួយចំនួនដែលផ្ដល់ផលិតផលបន្ថែមក្រៅពីឈើ

ទំព័របន្ថែមទី១: ការគណនាតំរូវការគ្រាប់ពូជឈើ

# ៨. ប្រព័ន្ធកសិរុក្ខកម្ម*

## ៨.១ យុត្តិកម្ម

កសិរុក្ខកម្ម គឺជាប្រព័ន្ធកសិកម្មមួយដែលរួមបញ្ចូលដោយដើមឈើ និង ដំណាំកសិកម្មហើយជួនកាលមានរួមបញ្ចូលដោយបសុសត្វផងដែរនៅលើផ្ទៃដីតែមួយ ។

ការអនុវត្តន៍ប្រព័ន្ធកសិរុក្ខកម្មអាចនឹងជួយបង្កើនប្រាក់ចំណូលប្រចាំឆ្នាំរបស់កសិករ តាមរយៈការប្រមូលផលពីដើមឈើផ្សេងៗគ្នា នៅក្នុងរដូវខុសៗគ្នា ដែលជាលទ្ធផលកសិករអាចរកប្រាក់ចំណូល និងមានការងារធ្វើនៅពេញមួយឆ្នាំ ។ មានហេតុផលជាច្រើនទៀតដែលនាំឱ្យមានការដាំដើមឈើនៅក្នុងចំការដំណាំ ដូចជាតំរូវការម្លប់សំរាប់ធ្វើឱ្យដីត្រជាក់ ការកាត់បន្ថយការបាត់បង់សំណើមដី ការពារដីពីសំណឹកដោយសារខ្យល់និងទឹក ។ ការអនុវត្តន៍ប្រព័ន្ធកសិរុក្ខកម្មអាចនឹងជួយកាត់បន្ថយគ្រោះថ្នាក់នៃការខូចខាតផលដំណាំទាំងមូលតែម្ដង ឧទាហរណ៍ប្រសិនបើផលដំណាំមួយមុខត្រូវខូចខាតដោយសារសត្វល្អិតបំផ្លាញ ឬតំលៃនៅទីផ្សារធ្លាក់ចុះ កសិករនៅអាចពឹងផ្អែកទៅលើផលិតផលផ្សេងៗទៀត ។

នៅក្នុងករណីជាច្រើនវិធីសាស្ត្រដែលងាយស្រួលបំផុតក្នុងការបង្កើតប្រព័ន្ធកសិរុក្ខកម្ម គឺត្រូវផ្ដោតអារម្មណ៍លើការដាំដំណាំដែលផ្ដល់ផលិតផលមិនមែនឈើនិងមានប្រភពមកពីព្រៃ ។ សំរាប់អ្នកអនុវត្តន៍ប្រព័ន្ធកសិរុក្ខកម្ម ដំណាំដែលផ្ដល់ផលិតផលមិនមែនឈើ គឺជាដំណាំដែលដាំនៅស្រទាប់ក្រោម ហើយការដាំដំណាំប្រភេទនេះនឹងផ្ដល់ឱកាសបង្កើតឱ្យមានប្រព័ន្ធកសិរុក្ខកម្មនៅក្នុងសហគមន៍ ឬមានន័យម្យ៉ាងទៀតថាបង្កើតព្រៃឈើនៅលើដីចំការរបស់កសិករ ។ បច្ចេកទេសគ្រប់គ្រងសំខាន់បំផុត ដើម្បីសំរេចគោលបំណងនេះគឺការដាំបញ្ចូលទៅក្នុងចំការដំណាំនូវប្រភេទឈើ ដែលផ្ដល់ផលិតផលមិនមែនឈើ ។

---

*(*): ផ្នែកនេះដកស្រង់និងសំរួលពី Kathleen et al, 1999*